ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងព្រហ្មទណ្ឌលេខ៨៣៩
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០២០
សាលក្រមលេខ ១៣៤ "ខ"
ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ដោយមានសមាសភាព ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ប្រធានក្រុមប្រឹក្សា
លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៣៩ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] ធូម៉ា ភេទប្រុស អាយុ១៧ឆ្នាំ មុខរបរបើកបរកង់បី សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង, ឪពុកឈ្មោះ [redacted] ធឿន (ស) ម្តាយឈ្មោះ [redacted] ម៉ុម (ស) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០២០ ។
ឃុំខ្លួនថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២០ ។

២. ឈ្មោះ [redacted] ខេម ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្ត កំពង់ឆ្នាំង ឪពុក ឈ្មោះ [redacted] ជន (រ) ម្តាយឈ្មោះ [redacted] ស្រីវិទ្ធិ (រ) ប្រពន្ធឈ្មោះ [redacted] ចា (លែងលះ) ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។



Scanned with CamScanner

ឃាត់ខ្លួនថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០២០ ។

ឃុំខ្លួនថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២០ ។

៣.ឈ្មោះ [redacted] **សុវណ្ណតូរ៉ា** ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ចាន់ (ស) ម្តាយឈ្មោះ [redacted] ចាន់ធឿន (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ ។

ឃុំខ្លួនថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ។

៤. ឈ្មោះ [redacted] **ផាន់ណារ៉ាក់** ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ផល (ស) ម្តាយឈ្មោះ [redacted] ឃឹម (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ឃុំខ្លួនថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ។

៥. ឈ្មោះ [redacted] **ម៉េងហ៊ុយ** ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើ[redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្នភូមិតាំងគ្រង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] លីហៀង (ស) ម្តាយឈ្មោះ [redacted] សៅរី (ស) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ឃុំខ្លួនថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០២១ ។

៦. ឈ្មោះ [redacted] **ចាន់ធឿន** ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើ[redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្នភូមិស្រះចក ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ឪពុក ឈ្មោះ [redacted] សារាំង (រ) ម្តាយឈ្មោះ [redacted] ម៉ារ៉ា (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន ។

ឃុំខ្លួនថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០២១ ។

៧.ឈ្មោះ [redacted] **ឧត្តម** ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្នភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ ឆ្នាំង ឪពុកឈ្មោះ [redacted] សារ៉ាក់ ម្តាយឈ្មោះ [redacted] ម៉ាប់ នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។



Scanned with CamScanner

ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១៩៨៤/២០២០ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងកំពង់ឆ្នាំង។

៨.ឈ្មោះ [redacted] កុសល ហៅ ញ៉ៀល ភេទប្រុស អាយុ១៥ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ម៉ៅ(រ) ម្តាយឈ្មោះ [redacted] ចិប(រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសគ្មាន។

ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១៩៨៥/២០២០ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងកំពង់ឆ្នាំង

ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅតាមដងផ្លូវជាតិលេខ៥ ចំណុចស្ពានទី១ និងភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ ភូរ៉ា**

លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ុយ**, ឈ្មោះ [redacted] **ចាន់ធឿន**, ឈ្មោះ [redacted] **ផាន់ណារ៉ាក់**

លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ខេម**

លោកស្រីមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ធូម៉ា**

លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឧត្តម** និងជនជាប់ចោទឈ្មោះ [redacted] **កុសល់**

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៧៤៧ អ.យ/២១ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

បានឃើញ ដីកាដំណោះស្រាយលេខ ៥៨៤/២០២១ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ២០ និង ០០ នាទី នៅចំណុចស្ពានទី១ និងថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង០៧និង៣០នាទី នៅការ៉ាស់សាំងPTT ស្ថិតនៅភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ ត្រឡាច ខេត្តកំពង់ឆ្នាំង កើតមានករណីអំពើលួចមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយ ១.ឈ្មោះ [redacted] សុវណ្ណភូរ៉ា ហៅ រ៉ា ២.ឈ្មោះ [redacted] ធូម៉ា ហៅ តួម៉ា



Scanned with CamScanner

៣.ឈ្មោះ [redacted] ជេម ហៅ ង៉ោ ៤.ឈ្មោះ [redacted] ឧត្តម ៥.ឈ្មោះ [redacted] កុសល់ ៦.ឈ្មោះ [redacted] ម៉េងហ៊ុយ ៧.ឈ្មោះ [redacted] ចាន់ធឿន ៨.ឈ្មោះ [redacted] ផាន់ណាក់ បានធ្វើ សកម្មភាពលួចឆក់ទូរស័ព្ទ កាបូប ខ្សែរក នៅតាមដងផ្លូវជាតិលេខ ០៥។

## នាពេលសវនាការ

ជនត្រូវចោទឈ្មោះ [redacted] សុវណ្ណភូរ៉ា បានឆ្លើយថា៖ នៅពេលកើតហេតុខ្លួននៅផ្ទះជួលជាមួយ សង្សារ លុះព្រឹកឡើងសមត្ថកិច្ចចុះចាប់តែម្តង។ មុននោះខ្លួនបានឆក់គេនៅម្តុំផ្សារត្រាច ដោយជិះម៉ូតូ ម៉ាកសង់ពណ៌ខ្មៅឆ្នាំ២០០៨ ដោយមានគ្នាពីរនាក់ ជាមួយឈ្មោះ [redacted] ចាន់ធឿន ដែលមានរូបខ្លួនជា អ្នកឌុប ពេលនោះម៉ោង ១២យប់ ដោយខ្លួនជិះម៉ូតូយកដៃឆក់យកពេលគេជិះម៉ូតូដែរ ដោយទូរសព្ទ គេដាក់ក្នុងហោប៉ៅក្រោយ ដោយខ្លួនបើកម៉ូតូ ចាន់ធឿន ជាអ្នកឆក់។ ពេលឆក់បានគឺយកមកប្រើ មិនបានយកទៅលក់នោះទេ។ ខ្លួនមិនដឹកប្រព្រឹត្តទេ ទើបតែជាលើកទីមួយ។ ឈ្មោះ [redacted] សុវណ្ណភូរិន ត្រូវជាប្អូនខ្លួនរៀននៅវិទ្យាល័យសាលាលេខប្រាំ ស្នាក់នៅជាមួយខ្លួន ហើយខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ជេម ទេ។ ពីដំបូងខ្លួនឆក់ម្តងបាន OPPO មួយគ្រឿង ឆក់លើកទីពីរ និងទីបី មិនទទួលបានអ្វីទេ លើកទីបួន ឆក់បាន ABS មួយគ្រឿង កាលពីថ្ងៃទីដប់មួយ ហើយដំបូងគេក៏កាលខែដប់មួយដែរ គឺក្នុងមួយខែធ្វើសកម្មភាពបួន ដង។ អ្នកឆក់ជាមួយមានឈ្មោះ [redacted] ចាន់ធឿន ដោយម៉ូតូជារបស់ ចាន់ធឿន ព្រោះខ្លួនឃើញគាត់ជិះតែម៉ូតូនេះទេ ដោយខ្លួនទើបស្គាល់គាត់កាលខែដប់មួយនេះទេ។ ខ្លួនស្គាល់ឈ្មោះ ចាន់ធឿន មិនច្បាស់ប៉ុន្មានទេ តែគាត់ពិតជាបានឆក់ជាមួយខ្លួនមែន។ នៅក្នុងខែមីនា ខ្លួនធ្លាប់ឆក់ទូរសព្ទនៅទីតាំងដដែលជាមួយឈ្មោះ [redacted] ចាន់ធឿន ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ធឿន នៅខែដប់មួយ ឆ្នាំ២០២០ និងឈ្មោះ [redacted] ធូម៉ា។ ចំពោះចម្លើយដែលឆ្លើយនៅចៅក្រមស៊ើបសួរ ជាចម្លើយមិនពិតប្រាកដ។ ឈ្មោះ [redacted] ធូម៉ា ខ្លួនមិនស្គាល់ទេ គឺស្គាល់តែធូម៉ា នៅខែដប់មួយ ឆ្នាំ២០២០ ដោយបានហូបចុកជាមួយគ្នា។ ខ្លួនបានរៀនត្រឹមថ្នាក់ទី៣ មិនចេះរាប់ខែឆ្នាំទេ ខែវិច្ឆិកាមិនដឹងថាខែប៉ុន្មានទេ ហើយខែមីនាក៏មិនដឹងដែរ។ ខ្លួនមិនស្គាល់ពីការរាប់ខែទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ធឿន មុនពេលឆក់នៅខែដប់មួយ តែមិនដឹងថាខែអ្វីទេ។ ពេលឆក់គឺ ស្រុះស្រួលគ្នា ទៅឆក់ទាំងពីរនាក់ ហើយពេលឆក់ជនរងគ្រោះមិនបានរងរបួសអ្វីនោះទេ ហើយក៏ មិនបានឥវ៉ាន់អ្វីផ្សេងដែរ ដោយគេកាន់នឹងដៃដែលបង្ករភាពងាយស្រួលក្នុងការឆក់។ ខ្លួនស្គាល់ឈ្មោះ រិន ធូម៉ា តាមរយៈឈ្មោះ សុវណ្ណភូរ៉ា គឺក្រោយស្គាល់ឈ្មោះ ចាន់ធឿន។ ខ្លួនស្គាល់ឈ្មោះ ចាន់ធឿន មុនពេលលួចហើយនៅក្នុងពន្ធនាគារមានកើតរមាស ហើយនឹកដល់ក្រុមគ្រួសារដោយជាប់បានប្រាំបួន

ខែ។ ខ្លួនបានដឹងថាទង្វើនេះខុសច្បាប់ ហើយតុលការដោះលែងសុំសន្យាថាលែងប្រព្រឹត្តទៀតហើយ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឧត្តម ជាអ្នករៀនជាមួយគ្នា ឈ្មោះ កុសល ខ្លួនស្គាល់ ហយពីរនាក់នេះមិនមានពាក់ពន្ធនិងរឿងនេះទេ។ ខ្លួនមិនមានម៉ូតូផ្ទាល់ខ្លួនទេ។ ពេលកើតហេតុខ្លួនខ្លួនអ្នកបើកម៉ូតូឈ្មោះ [redacted] ចាន់ឌឿនអ្នកឆក់ ខ្លួនមិនដែររស់នៅជាមួយគ្នាទេ។ មូលហេតុដែលនាំគ្នាទៅឆក់ គឺពេលស្រវឹងហើយខ្លួនអ្នកបើកម៉ូតូ ព្រោះខ្លួនមិនចង់ឱ្យឈ្មោះ [redacted] ចាន់ឌឿន អ្នកបើកគឺអោយគាត់អ្នកឆក់។ ពេលឆក់បានគាត់សុំទូរសព្ទទៅស្រី។ ម៉ូតូរបស់ [redacted] ធូម៉ា បានជិះធ្វើសកម្មភាពបានបួន ដង។ ខ្ញុំស្គាល់ឈ្មោះ [redacted] ធូម៉ា កាលរៀនណៅជាមួយគ្នា។

ជនត្រូវចោទឈ្មោះ [redacted] ធូម៉ា បានឆ្លើយថា៖ ខ្លួនត្រូវបានឃាត់ខ្លួននៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ ពេលដែលឃាត់នោះខ្លួននៅជាមួយឈ្មោះ [redacted] ភូរិន នៅហាងកាហ្វេ ដោយគេប្រាប់ថា ទៅបំភ្លឺរឿងគប់ផ្ទះសំណាក់ ហើយគេប្រាប់ថាអ្នកជាប់បីនាក់ ឆ្លើយដាក់ខ្លួន។ ខ្លួនម៉ូតូម៉ាកសង់ ឆ្នាំ២០១៨ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1H-9598 ជាម៉ូតូម្តាយខ្លួនដែលខ្លួនជិះ។ ខ្លួនបានជិះបានមួយឆ្នាំពេលខ្លួនចេញពីមណ្ឌលអប់រំមកវិញ។ ឈ្មោះ [redacted] ចាន់ឌឿន បានខ្ចីម៉ូតូពីខ្លួននៅពេលផឹកស៊ីជាមួយគ្នាដោយគាត់បានខ្ចីជិះមកទិញសាច់ក្អែមមានគ្នាបីនាក់ក៏ត្រូវគេចាប់តែម្តង។ គេខ្ចីម៉ូតូខ្លួនមុនពេលគេឃាត់ខ្លួន៧ថ្ងៃ។ ខ្លួនស្គាល់គ្នានៅកន្លែងផឹកស៊ីដែលមានគ្នាខ្លួន៤នាក់ មានឈ្មោះ [redacted] សុផាន់ណា អែមេងហុយ [redacted] ចាន់ឌឿន និងខ្លួន។ ផឹកមុនដំបូងខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ឌឿន មុនគេ ពេលផឹកស៊ីជាមួយគ្នាមុនពេលគេឃាត់ខ្លួនបានមួយអាទិត្យ។ ខ្លួនស្គាល់គាត់តែមិនដែរបានដើរជាមួយគាត់ទេ ពេលផឹកស៊ីខ្លួនមិនស្គាល់សុវណ្ណភូវ៉ាទេ។ ខ្លួនស្គាល់ឈ្មោះ សុវណ្ណភូវ៉ា កាលរៀនថ្នាក់ទី៣។ ពេលផឹកស៊ីក៏បានហៅខ្លួនក្នុងលក្ខណៈស្គាល់គ្នាដោយផឹកស៊ីអស់ មួយទៅពីរកំប៉ុង ពេលដែលហៅនោះមានឈ្មោះ [redacted] ចាន់ណាក់ ឈ្មោះ [redacted] ម៉េងហ៊ុយ ដោយខ្លួនស្គាល់មុនមួយអាទិត្យ គឺមុនពេលផឹកស៊ីជាមួយគ្នា។ ដោយសារស្គាល់គាត់ទើបខ្លួនហ៊ានឱ្យខ្ចីម៉ូតូទៅទិញសាច់ក្អែម ពេលគាត់ជិះទៅត្រូវបានគេឃាត់ខ្លួន។ ម៉ូតូខ្លួនអត់ស្លាកលេខទេ ដោយសារតែដួលបែកអាវ ម៉ូតូខ្លួនសេរី០១៨ឡើងតែម០២០ ជាម៉ូតូដែលខ្លួនឱ្យឈ្មោះ [redacted] ឌឿន ខ្ចី ហើយម៉ូតូមួយគ្រឿងទៀតគឺដកហូតពេលចាប់ខ្លួននៅហាងកាហ្វេ។ពេលជិះចេញទៅមានគ្នាបីនាក់តែស្គាល់តែឈ្មោះ វ៉ាន់ឌឿន ម្នាក់ទេ។ ម៉ូតូស្លាកលេខ 1H-9599 ជាម៉ូតូ០១៨ ឡើងតែមជា០២០។ ម៉ូតូដែលខ្លួនជិះជាប់លាប់គឺជាម៉ូតូអត់ស្លាកលេខ ហើយអត់ពន្ធ។

ជនត្រូវចោទឈ្មោះ [redacted] ឌេម បានឆ្លើយថា៖ ពេលសមត្ថកិច្ចចាប់ខ្លួន គឺខ្លួនបាទនៅក្នុងបន្ទប់ឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ា ។ពេលគេចាប់នោះគឺមកសួរនាំរឿងគប់កញ្ចក់ផ្ទះគេ តែខ្លួនមិនបានប្រព្រឹត្តនោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ឌឿន ពេលរាំផុងបាស់ជាមួយគ្នាយូរហើយជាមួយឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ា ឈ្មោះ ដាញ៉ែល ស្គាល់គ្នាបានដើរលេងជាមួយគ្នាបានម្តង។ ខ្លួនគ្មានម៉ូតូជិះទេ គឺឈ្មោះ ដាញ៉ែល មកយកដោយជិះម៉ូតូសង់០២០ពណ៌ក្រហម មិនចាំស្លាកលេខ ដោយបានមកយកខ្លួនបានម្តង។ ខ្លួននៅចំការស្វាយ ឃុំសេដ្ឋី មិនដែរប្តូរលំនៅដ្ឋានទេ។ ពេលចាប់ខ្លួននៅផ្ទះជួលឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ា ដោយពីផ្ទះខ្លួនទៅដល់នោះមានប្រវែងប្រហែល ១០០០ ម៉ែត្រ។ មុនដំបូងបងថ្លៃខ្លួនឌុបខ្លួនទៅហាងកាហ្វេ ហើយខ្លួនទៅផ្ទះ [redacted] សុវណ្ណភ្ញូវ៉ា ដើម្បីខ្ចីទូរសព្ទខលទៅបងឱ្យជូនទៅភ្នំពេញ តែត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ខ្លួនធ្លាប់ស្គាល់គ្នាពេលរាំផុងបាស់ ដោយរាប់អានគ្នាជាមិត្តភ័ក្រតាមទូរសព្ទរឿងញ៉ែស្រី។ កាលទាក់ទងគ្នាតាមទូរសព្ទគឺទាក់ទងកាលខ្លួននៅភ្នំពេញ ក្រោយមកខ្លួនបានលក់វាចោលពេលត្រឡប់មកវិញ។ ឈ្មោះ [redacted] ធូម៉ា ស្គាល់បានម្តង ពេលនៅហាងកាហ្វេពេលផឹកជាមួយឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ា។ ខ្លួនមិនដឹងរឿងនោះទេ ចំពោះការធ្វើសកម្មភាពឆក់នោះតែដឹងត្រឹមតែឈ្មោះ ឧត្តម ឈ្មោះ កុសល ប្រាប់ថាចេញធ្វើសកម្មភាពតែមិនដែលឃើញសកម្មភាពឆក់ទេ។ ខ្លួនមិនដែលមានទំនាស់ជាមួយគ្នាពីមុនមកទេ។កាលនៅសមត្ថកិច្ចគឺខ្លួនឆ្លើយទាំងភ័យ។

ជនត្រូវចោទឈ្មោះ [redacted] **ចាន់ឿន** បានឆ្លើយថា៖ គេឃាត់ខ្លួនរឿងគប់កញ្ចក់ផ្ទះ តែខ្លួនមិនបានដឹងរឿងអ្វីទេ។ ចំពោះការកាស់ផ្ទះខ្លួនទទួល តែមិនចាំថ្ងៃកាលពីខែ១១ ឆ្នាំ២០២០។ ខ្លួនមិនដែលត្រូវបានឆក់ទូរសព្ទគេទេ។ ឈ្មោះ [redacted] ធូម៉ា ឈ្មោះ សុវណ្ណភ្ញូវ៉ា ទើបស្គាល់ពេលស៊ីផឹក ក្នុងខែ១១ ថ្ងៃទី២៥ នៅថ្ងៃកើតហេតុដោយថ្ងៃនោះបានខ្ចីម៉ូតូពីឈ្មោះ [redacted] ធូម៉ា ចំនួនពីរដង លើកទីមួយកាលថ្ងៃទី២៥ ខែ១១ ឆ្នាំ២០២០ ដោយខ្ចីពេលថ្ងៃមួយភ្លេតតែម្នាក់ឯង។ នៅក្នុងវង់ផឹកស៊ីមានគ្នាច្រើនមានឈ្មោះ [redacted] ម៉េងហ៊ុយ [redacted] ផាន់ណាក់។ ខ្លួនបានខ្ចីម៉ូតូឈ្មោះ [redacted] ធូម៉ា លើកទីមួយទៅផ្ទះប្រហែល២០នាទី លុះដល់យប់បានខ្ចីម្តងទៀតនៅម៉ោង១១យប់ដោយកំពុងផឹកស៊ីនៅហាង៩៩ នៅកំពង់ត្រឡាច ដោយខ្ចីទៅខារ៉ាអូខេ មានគ្នា៣នាក់ មានឈ្មោះ [redacted] ផានណាក់ ឈ្មោះ [redacted] ម៉េងហ៊ុយ និងខ្លួន មិនមានឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ា។ ចម្លើយដែលខ្លួនឆ្លើយនៅនគរបាលយុត្តិធម៌ គឺត្រឹមត្រូវជាបានការ ហយនៅចៅក្រមស៊ើបសួរក៏ត្រឹមត្រូវដែល។ ខ្លួនធ្លាប់ឈ្លោះប្រកែកគញ្ញានារឿងវាឆ្លើយដោយហៅខ្លួនអា១ ទើបតែស្គាល់សោះជាមួយ [redacted] សុវណ្ណភ្ញូវ៉ា ពេលនៅហាងផឹកស៊ី ៩៩ តែវាមិនបានទៅខារ៉ាអូខេជាមួយខ្លួនទេ។ ពេលផឹកស៊ីមានឈ្មោះ [redacted] សុវណ្ណភ្ញូវ៉ាដែរ។ ថ្ងៃចាប់គឈ២៥

ខែ១១ ឆ្នាំ២០២០ មានឈ្មោះ [redacted] ម៉េងហ៊ុយ និងឈ្មោះ [redacted] ផាន់ណាក់។ ខ្លួនស្គាល់គ្នាតាមរយៈស្រីនៅទីនោះ ដោយពួកខ្លួនស្គាល់គ្នានៅខាងក្រៅ ហើយទើបនាំគ្នាទៅផឹកស៊ីនៅហាងខារ៉ាអូខេ៩៩។ ម៉ូតូម៉ាកឌ្រីម មិនដឹងស៊េរីឆ្នាំទេ ដឹងតែជិះពណ៌ខ្មៅ។ បុគ្គលឈ្មោះ [redacted] ធូម៉ា គឺស្គាល់មុនបីទៅបួនថ្ងៃនៃថ្ងៃឃាត់ខ្លួន ស្គាល់ដោយផឹកស៊ីជាមួយគ្នាទាំងប្រាំមួយនាក់ មានឈ្មោះ [redacted] ធូម៉ា [redacted] សុវណ្ណភូរ៉ា ឈ្មោះ [redacted] ម៉េងហ៊ុយ ឈ្មោះ [redacted] ផាន់ណាក់ ឈ្មោះ [redacted] ជេម និងខ្លួន ដោយស្គាល់គ្នាតាមរយៈស្រីជាសង្សារ មុនពេលឃាត់ខ្លួនបានខ្ចីម៉ូតូផងដែរ ដោយមានថ្ងៃកើតហេតុធ្លាប់ខ្ចីម្តងទៅផ្ទះងូតទឹក។

ជនត្រូវចោទឈ្មោះ [redacted] **ផាន់ណាក់** បានឆ្លើយថា ពេលឃាត់ខ្លួនមានគ្នាបីនាក់ មានឈ្មោះ [redacted] ចាន់ឌឿន ឈ្មោះ [redacted] ម៉េងហ៊ុយ នឹងខ្លួន។ ស្គាល់គ្នាកាលខែ១១ ពេលផឹកស៊ីជាមួយគ្នា ហើយមិនមានអ្នកផ្សេងទៀតទេ។ ថ្ងៃឃាត់ខ្លួនគឺជិះម៉ូតូរបស់ឈ្មោះ [redacted] ធូម៉ា ទៅទិញសាច់ក្ដែម ប្រហែលម៉ោង ១០យប់ តែមិនចាំថ្ងៃ តែទិញមិនបានហើយជិះទៅរកទិញទៀតត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ពេលផឹកមានគ្នាប្រាំនាក់មានឈ្មោះ [redacted] ចាន់ឌឿន ឈ្មោះ [redacted] ម៉េងហ៊ុយ ឈ្មោះ [redacted] ធូម៉ា ឈ្មោះ [redacted] សុវណ្ណភូរ៉ា និងខ្លួន។ ចម្លើយដែលឆ្លើយកន្លងមកនៅនគរបាលយុត្តិធម៌ នៅអយ្យការ និងចៅក្រមស៊ើបសួរ ទុកទៅជាបានការដដែល។ មុនពេលគេឃាត់ខ្លួន គឺខ្លួនរកស៊ីនៅប្រទេសថៃ រហូតដល់ខែប្រាំមួយទើបចូលស្រុកខ្មែរវិញតាមច្រកឡែម។ ពួកខ្លួនស្គាល់គ្នានៅពេលផឹកស៊ីនៅហាង៩៩។ ពេលផឹកស៊ីចេញលុយចូលគ្នា ខ្លួនធ្លាប់ផឹកស៊ីជាមួយគ្នា ហើយបានទៅទិញសាច់ក្ដែមជាមួយឈ្មោះ [redacted] ចាន់ឌឿន និងឈ្មោះ ម៉េងហ៊ុយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ហើយមិនបានទៅច្រៀងខារ៉ាអូខេទេ ដោយខ្លួនជាអ្នកឌុបមិនបានស្រវឹងទេ។ ម៉ូតូនោះជារបស់ [redacted] ធូម៉ា។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] សុវណ្ណភូរ៉ា ទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ធូម៉ា ពេលផឹកស៊ី ចំពោះឈ្មោះ [redacted] ចាន់ឌឿន ទើបតែស្គាល់បានមួយអាទិត្យ។ ចំពោះឆ្លើយនេះជាចម្លើយត្រឹមត្រូវនិងច្បាស់លាស់។ ពេលផឹកស៊ីអ្នកបបួលគេទៅខារ៉ាអូចេគឺឈ្មោះ ចាន់ឌឿន ។ នៅថ្ងៃផឹកស៊ីនោះ ខ្លួនបានខ្ចីម៉ូតូឈ្មោះ [redacted] ធូម៉ា តែម្តងទេ។

ជនត្រូវចោទឈ្មោះ [redacted] **ម៉េងហ៊ុយ** បានឆ្លើយថាៈ ខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ឌឿន នៅខួងខែ១១ ។ ខ្លួនមិនដែលបានផឹកស៊ីជាមួយទេ គឺគ្រាន់តែជិះមូតូជួបមុខគ្នាក៏បានរាប់អានគ្នាទៅ។ កាលនោះខ្លួនចង់ជួបជុំពួគាត់បានម្តង ពេលទៅខារ៉ាអូខេ មិនមានអ្នកណាឈ្លោះគ្នាទេ ខ្លួនមិនស្គាល់ម្ចាស់ម៉ូតូ។ ខ្លួនមិនស្គាល់ ចាន់ ឌឿន និងឈ្មោះ ណាក់ ពីមុនមកទេឬក៏ទទួលបានផលប្រយោជន៍។

**តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថ្កោលទោស**

ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ ឃើញថា កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ២០ និង ០០ នាទី នៅចំណុចស្ពានទី១ និងថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង០៧និង៣០នាទី នៅការ៉ាស់សាំងPTT ស្ថិតនៅភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ ត្រឡាច

ខេត្តកំពង់ឆ្នាំង កើតមានករណីអំពើលួចមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយ ១.ឈ្មោះ [redacted] សុវណ្ណភ្ញាំ ហៅ រ៉ា ២.ឈ្មោះ [redacted] ធូម៉ា ហៅ តូម៉ា ៣.ឈ្មោះ [redacted] ដេម ហៅ ង៉ោ ៤.ឈ្មោះ [redacted] ឧត្តម ៥.ឈ្មោះ [redacted] កុសល់ ៦.ឈ្មោះ [redacted] ម៉េងហ៊ុយ ៧.ឈ្មោះ [redacted] ចាន់ធឿន ៨.ឈ្មោះ [redacted] ផាន់ណាក់ បានធ្វើសកម្មភាពលួចឆក់ទូរស័ព្ទ កាបូប ខ្សែរក នៅតាមដងផ្លូវជាតិលេខ០៥ ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការនៅតែតម្កល់ ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៧៤៧ អ.យ/២១ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២១ របស់ តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងហ៊ុយ, [redacted] ចាន់ឌឿន និងឈ្មោះ [redacted] ផាន់ណាក់ បានធ្វើសេចក្តីសន្និដ្ឋានការពារថា**

សកម្មភាពរបស់កូនក្តីខ្លួនឈ្មោះ [redacted] ម៉េងហ៊ុយ បើពិនិត្យពីចម្លើយរបស់ជនជាប់ចោទ ឃើញថា មានវិមតិសង្ស័យទៅហើយ ថាគាត់ ឆក់ សមគំនិត ធ្វើសកម្មភាពឆក់នោះទេ ព្រោះពួកគាត់ទើបតែស្គាល់គ្នា ហើយពួកគេមិនមានទំនាក់ទំនងនៅហ្នឹងកន្លែងកើតហេតុនោះទេ។ ដូចនេះ នាំឱ្យគ្មានអង្គហេតុឆក់នោះទេ ចំណែកឈ្មោះ [redacted] ចាន់ឌឿន ចំពោះចម្លើយថាឈ្មោះ [redacted] ចាន់ឌឿន ឆក់ជាមួយនោះជាចម្លើយដាក់បន្ទុក ព្រោះពាក់ព័ន្ធនិងកាលបរិច្ឆេទ កម្មវត្ថុនៃការឆក់ គឺមិនមាន ពាក់ព័ន្ធនោះទេ គឺឈ្មោះ [redacted] សុវណ្ណភ្ញាំ មានប្អូនម្នាក់ទៀតដែលរស់នៅជាមួយ ចំពោះម៉ូតូនោះ ក៏មិនត្រឹមត្រូវដែរព្រោះម្ចាស់ម៉ូតូឆ្លើយថាបានខ្ចីតែម្តងទេ ចំណែកឈ្មោះ [redacted] ផាន់ណាក់ ដូចគ្នាទៅ នឹងឈ្មោះ [redacted] ម៉េងហ៊ុយ ដែរគឺគ្មានចម្លើយណាមួយដែលបញ្ជាក់ថាគាត់ប្រព្រឹត្តនោះទេ។ ហេតុ ដូចនេះប្តឹងសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យរួចផុតបទចោទចំពោះកូនក្តីខ្លួនទាំងបីនាក់។

**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណភ្ញាំ បានធ្វើសេចក្តីសន្និដ្ឋានថា**

ក្រោយពីបានសិក្សាលើសំណុំរឿង និងចម្លើយសារភាពរបស់កូនក្តី ឃើញថាកូនក្តីរបស់ខ្លួន មានស្មារតីក្នុងការសារភាពអំពីការប្រព្រឹត្ត ហើយកូនក្តីរបស់ខ្លួនជាអនីតិជន ដែលបានឆ្លើយ មានការភ័ន្តច្រឡំ តែគាត់បានសារភាពថាការប្រព្រឹត្តនោះដោយហេតុគាត់មិនមានចំណេះដឹង និងបាន សន្យាថានិងកែប្រែកំហុស ហេតុនេះស្នើសុំប្រធានក្រុមប្រឹក្សាមេត្តាសម្រេចផ្តល់ស្ថានសម្រាល ដោយក្តីអនុគ្រោះ។

**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដេម បានធ្វើសេចក្តីសន្និដ្ឋានថា**

ក្នុងរឿងនេះកូនក្តីខ្លួនគ្រាន់តែជាអ្នកស្គាល់គ្នា ហើយមិនបានចូលរួមឆក់នោះទេ ហើយចម្លើយ របស់ឈ្មោះ សុវណ្ណភ្ញាំ ក៏បានបញ្ជាក់ផងដែរថា មិនបានចូលរួមទេ គឺគេគ្រាន់តែទៅផឹកស៊ី និងបាន ឱ្យលុយម្តង ៣០០០០ (បីម៉ឺន) រៀល ទៅ៥០០០០ (ប្រាំម៉ឺន)រៀល ហើយបានមកឃាត់ខ្លួនកូន



Scanned with CamScanner

ក្តីខ្លួននៅក្នុងបន្ទប់ជួលនេះទេ។ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ ហេតុនេះប្តឹងសុំក្រុមប្រឹក្សា លើកលែងបទចោទលើកូនក្តីខ្លួន។

**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] កុសល បានធ្វើសេចក្តីសន្និដ្ឋានថា**

អង្គហេតុខាងលើពាក់ព័ន្ធនិងអំពើលួចពីរករណីគឺកាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ ដែលមានទីតាំងខុសគ្នា។ ពេលកើតហេតុពុំមានករណីជាក់ស្តែងទេ គឺស្រាវជ្រាវឃាត់ខ្លួនបានគ្នា ៦នាក់ ហើយក្នុងរបាយការណ៍ថាកូនក្តីខ្លួនរត់គេចខ្លួន។ នៅក្នុងតំណាក់កាលអយ្យការឈ្មោះ [redacted] ជេម ឈ្មោះ សុវណ្ណភៅរ៉ា បានឆ្លើយដាក់បន្ទុកមកលើកូនក្តីខ្លួនថាបានដឹងពីការចេញធ្វើសកម្មភាព ដោយឡែកឈ្មោះ [redacted] ចាន់ឌឿន បានឆ្លើយថាមិនបានស្គាល់កូនក្តីខ្លួននោះទេ។ មិនមានអង្គហេតុស៊ីសង្វាក់គ្នាថាកូនក្តីខ្លួន បានប្រព្រឹត្តលើអង្គហេតុណាមួយខាងលើនោះទេ ។ ការចោទប្រកាន់សំអាងលើចម្លើយរបស់ឈ្មោះ [redacted] ជេម នោះគ្មានភស្តុតាងគ្រប់គ្រាន់ទេ ។ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ។ ដោយហេតុថា កូនក្តីខ្លួនមិនមានពាក់ព័ន្ធ និងអង្គហេតុណាមួយខាងលើ និងមានវិមតិតសង្ស័យផងនោះ ស្នើសុំប្រធានក្រុមប្រឹក្សា សម្រេចលើកលែងចោទលើកូនក្តីខ្លួន។

**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា បានធ្វើសេចក្តីសន្និដ្ឋានថា**

យោងតាមអង្គហេតុនឹងអង្គច្បាប់ បញ្ជាក់យ៉ាងច្បាស់ថាឈ្មោះ [redacted] ធូម៉ា មិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះឡើយ។ ទោះបីឈ្មោះ [redacted] ធូម៉ា ធ្លាប់ខ្ចីម៉ូតូក៏ពិតប្រាកដមែន ប៉ុន្តែពុំមានន័យថា គាត់បានចូលរួមប្រព្រឹត្តបទល្មើសនោះទេ គ្រាន់តែជួបជុំផឹកស៊ីធម្មតាប៉ុណ្ណោះ។ ពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការដាក់ទោសកូនក្តីខ្លួន ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហឹង្សា តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនោះទេ។ ស្នើសុំឱ្យតុលាការសម្រេចឱ្យឈ្មោះ [redacted] ធូម៉ា រួចផុតពីបទចោទ និងរកយុត្តិធម៌ឱ្យកូនក្តីខ្លួន។

**ជនជាប់ចោទនិយាយសម្តីចុងក្រោយ**

ជនជាប់ចោទឈ្មោះ [redacted] ធូម៉ា សំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់។

ជនជាប់ចោទឈ្មោះ [redacted] ជេម សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយ និងលើកលែងចោទប្រកាន់។

ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណភូរ៉ា សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយព្រោះដឹងកំហុសហើយ។

ជនជាប់ចោទឈ្មោះ [redacted] ម៉េងហ៊ុយ សំណូមពរសុំតុលាការបន្ធូរបន្ថយព្រោះដឹងកំហុសហើយ។

ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន សំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ផង។

ជនជាប់ចោទឈ្មោះ [redacted] ផាន់ណាក់ សំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១. កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ២០ និង ០០ នាទី នៅចំណុចស្ពានទី១ និងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង០៧និង៣០នាទី នៅការ៉ាស់សាំងPTT ស្ថិតនៅភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ពិតជាមានករណីអំពើលួចមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយឈ្មោះ [redacted] សុវណ្ណភូរ៉ា ឈ្មោះ [redacted] ធូម៉ា ឈ្មោះ [redacted] ជេម ឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] កុសល ឈ្មោះ [redacted] ម៉េងហ៊ុយ ឈ្មោះ [redacted] ចាន់ធឿន ឈ្មោះ [redacted] ផាន់ណាក់ បានធ្វើសកម្មភាពលួចឆក់ទូរស័ព្ទ កាបូប ខ្សែរក នៅតាមដងផ្លូវជាតិលេខ ០៥ ប្រាកដមែន ។

២. ថ្វីត្បិតតែជនជាប់ចោទឈ្មោះ [redacted] ធូម៉ា ឈ្មោះ [redacted] ជេម ឈ្មោះ [redacted] ម៉េងហ៊ុយ ឈ្មោះ [redacted] ចាន់ធឿន ឈ្មោះ [redacted] ផាន់ណាក់ បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដែលចម្លើយរបស់ជនជាប់ចោទគឺគ្រាន់តែជាការឆ្លើយដោះសារតែប៉ុណ្ណោះ ព្រោះថាតាមចម្លើយរបស់ឈ្មោះ [redacted] សុវណ្ណភូម៉ា ឆ្លើយសារភាពថា ខ្លួនបានជិះម៉ូតូម៉ាកសង់ពណ៌ខ្មៅឆ្នាំ២០០៨ ដោយមានគ្នាពីរនាក់ ជាមួយឈ្មោះ [redacted] ចាន់ធឿន ដែលមានរូបខ្លួនជាអ្នកឌុប ពេលនោះម៉ោង១២យប់ ដោយខ្លួនជិះម៉ូតូយកដៃឆក់យកពេលគេជិះម៉ូតូដែរ ដោយទូរសព្ទគេដាក់ក្នុងហោប៉ៅក្រោយ ដោយខ្លួនបើកម៉ូតូ ចាន់ធឿន ជាអ្នកឆក់ ហើយស្របទៅនឹងរបាយការណ៍ សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗទៀត ដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់គួរឱ្យតុលាការជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ប្រាកដមែន ។

៣. ជនជាប់ចោទជានីតិជន និងជាសមត្ថជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌបានពោលគឺជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៤. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ធូម៉ា ឈ្មោះ [redacted] ជេម ឈ្មោះ [redacted] ម៉េងហ៊ុយ ឈ្មោះ [redacted] ចាន់ធឿន ឈ្មោះ [redacted] ផាន់ណាក់ និងឈ្មោះ [redacted] សុវណ្ណភូរ៉ា បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ យកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ផ្ទាល់ខ្លួន ប្រាកដមែន ។



Scanned with CamScanner

៥. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ធូម៉ា ឈ្មោះ[redacted]ជេម ឈ្មោះ[redacted]ម៉េងហ៊ុយ ឈ្មោះ[redacted]ចាន់ធឿន ឈ្មោះ[redacted] ផាន់ណាក់ និងឈ្មោះ[redacted] សុវណ្ណភូម៉ា ឈ្មោះ[redacted] ឧត្តម ឈ្មោះ[redacted]កុសល ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅតាមដងផ្លូវជាតិលេខ៥ ចំណុចស្ពានទី១ និងភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦. អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់ការពារ ។

៧. ជនជាប់ចោទឈ្មោះ[redacted] ធូម៉ា ឈ្មោះ[redacted]សុវណ្ណភូរ៉ា ឈ្មោះ[redacted]ម៉េងហ៊ុយ ឈ្មោះ[redacted] ភក្តិ និងឈ្មោះ[redacted]ផាន់ណាក់ ជាអនីតិជន គប្បីគុណាការសម្រេច អំពីស្វានសម្រាលទោសតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

ផ្តន្ទាទោស ៖

ក.ឈ្មោះ [redacted]**ធូម៉ា** ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ

ខ. ឈ្មោះ [redacted] **ជេម** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ

គ.ឈ្មោះ [redacted] **សុវណ្ណភូរ៉ា** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ

ឃ.ឈ្មោះ[redacted]**ម៉េងហ៊ុយ** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ

ង.ឈ្មោះ [redacted]**ចាន់ធឿន** ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ

ច.ឈ្មោះ [redacted]**ឧត្តម** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (បួន) ឆ្នាំ

ឆ.ឈ្មោះ [redacted]**កុសល** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ

ជ.ឈ្មោះ [redacted]**ផាន់ណាក់** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ

ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅតាមដងផ្លូវជាតិលេខ៥ ចំណុចស្ពានទី១ និងភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ តាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុវណ្ណភូរ៉ា ឈ្មោះ[redacted]ធូម៉ា ឈ្មោះ[redacted] ជេម ឈ្មោះ[redacted]ម៉េងហ៊ុយ, ឈ្មោះ

[redacted] ចាន់ធឿន នឹងឈ្មោះ [redacted] ផាន់ណាក់ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] កុសល, និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២១ ។

បើកសិទ្ធិប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

បានឃើញ

ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

កំពង់ឆ្នាំង, ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

[redacted]